**BMI0197**

## សម្ភាសន៍ជាមួយ អ៊ូច សុខុន ភេទស្រី អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ពេទ្យ

## ស្រុកកំណើតនៅភូមិដូនសរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

## រស់នៅភូមិកណ្ដាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឆាយ ឈុនលី

## ០១:១៣:៣២

## ២៧ទំព័រ

ឈុនលី : ជាដំបូងខ្ញុំសុំស្គាល់ឈ្មោះអ៊ី?

សុខុន : ឈ្មោះអ៊ូច សុខុន។

ឈុនលី : អាយុប៉ុន្មានហើយ?

សុខុន : អាយុ៥៤ ៥៥ហើយ។

ឈុនលី : នៅទីនេះភូមិអីគេអ៊ី?

សុខុន : ភូមិកណ្ដាល។

ឈុនលី : ស្រុកកំណើតនៅឯណាទៅ?

សុខុន : ស្រុកកំណើតអ៊ីនៅកៀនស្វាយ ភូមិដូនសរ ឃុំគគី ខេត្តកណ្ដាល។

ឈុនលី : អ៊ីមានបងប្អូនប៉ុន្មាននាក់?

សុខុន : ខ្ញុំមាន៩នាក់ ប្រុស៥ ស្រី៤។

ឈុនលី : ចុះឪពុកម្ដាយអ៊ីធ្វើអីគេ?

សុខុន : ឪពុកម្ដាយខ្ញុំកសិករ។

ឈុនលី : ឪពុកឈ្មោះអី?

សុខុន : ឈ្មោះ ហួរ ម្ដាយឈ្មោះ លន់

ឈុនលី : ចុះអ៊ីកើតនៅឆ្នាំណា?

សុខុន : ឆ្នាំ១៩៥៤។

ឈុនលី : អ៊ីបានរៀនសូត្រច្រើនទេ?

Documentation Center of Cambodia ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
Searching for the Truth: Memory & Justice
66 Preah Sihanouk Blvd. • P.O. Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

សុខុន ៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ទេ ។

ឈុនលី ៖ នៅសាលាអីទៅ?

សុខុន ៖ សាលាវត្តដូនសរ ។

ឈុនលី ៖ នៅវត្តហ្នឹង?

សុខុន ៖ ចាំ៎ នៅវត្តតែមានសាលា ។

ឈុនលី ៖ ចុះកាលមុនឆ្នាំ១៩៧៤ មុនខ្មែរក្រហមហ្នឹងអ៊ំធ្វើអីគេ?

សុខុន ៖ មុន៧៥ យើងនិយាយពី៧០មកវិញ ។

ឈុនលី ៖ ចាំ៎

សុខុន ៖ តាំងពីឆ្នាំ៧០ មកខ្ញុំនៅជាមួយឪពុកម្ដាយដល់ពេល៧៣ ខ្ញុំចូលធ្វើបដិវត្តិ ។

ឈុនលី ៖ មូលហេតុអីបានចូល?

សុខុន ៖ មូលហេតុគឺតស៊ូប្រឆាំចក្រព័ត្ធអាមេរិក ។

ឈុនលី ៖ ចុះពេលនោះមានបងប្អូនចូលរួមដែរអត់?

សុខុន ៖ បងប្អូនខ្ញុំចូលច្រើនណាស់ បងប្រុសខ្ញុំ ដួន ណារុណមួយ ។

ឈុនលី ៖ ស្រី ឬក៏ប្រុស?

សុខុន ៖ ប្រុស ។

ឈុនលី ៖ ចូលដំណាលគ្នាដែរអត់?

សុខុន ៖ អត់ទេបងខ្ញុំចូលតាំងពី៧០ឯណោះ ។

ឈុនលី ៖ ចុះមានអ្នកណាទៀត?

សុខុន ៖ មានខ្ញុំ អ៊ូច សុខុន ។

ឈុនលី ៖ ចុះមានអ្នកណាទៀត?

សុខុន ៖ មានប្អូនខ្ញុំមិនដឹងចូលថ្ងៃណាទេ ។

ឈុនលី ៖ ស្រីឬប្រុស?

សុខុន ៖ ប្រុស ។

ឈុនលី ៖ ចុះពេលចូលដំបូងធ្វើអីទៅ?

សុខុន ៖ ចូលទៅដំបូងគេឲ្យទៅធ្វើការនៅមន្ទីរពេទ្យ ។

ឈុនលី ៖ អូ! អ៊ំធ្វើពេទ្យដែរ ។

សុខុន ៖ មានពេទ្យ មានកសិកម្ម មានកាត់ដេរ សិប្បកម្ម មានគ្រប់សព្វទាំងអស់ ។

ឈុនលី ៖ មន្ទីរហ្នឹងនៅតាមព្រៃហ្អី?

សុខុន ៖ នៅតាមភូមិ គេហៅតំបន់រំដោះ ។

ឈុនលី ៖ នៅភូមិអីគេ?

សុខុន ៖ នៅភូមិពោធិ៍បាន ស្អាង កោះធំ ។

ឈុនលី ៖ ហើយនៅនោះហាត់រៀនអីចឹងទៅ?

សុខុន ៖ គេមានគ្រូពេទ្យវះកាត់តែចូលបានតែមួយរយៈខ្ញុំទៅនៅខាងឡូត៍នេសាទវិញ ។

ឈុនលី ៖ នៅបានរយៈពេលប៉ុន្មានដែរ?

សុខុន ៖ នៅបានជិតមួយឆ្នាំដែរ ។

ឈុនលី ៖ ចុះអឹចូលទៅហ្នឹងមានតួនាទីអីដែរ?

សុខុន ៖ អត់មានតួនាទីអីទេជាមហាជនធម្មតាមានអ្នកដឹកនាំ មានគណៈតំបន់អី ខ្ញុំនៅជាមួយតា សុខ ប៉ិតចំរើន ត្រូវជាមារបស់សម្ដេចតាយើងហ្នឹងតែគាត់ស្លាប់ហើយគាត់ធ្វើជាគណៈ តំបន់ ។

ឈុនលី ៖ គណៈតំបន់នៅខាងមន្ទីរពេទ្យ?

សុខុន ៖ គណៈតំបន់គាត់គ្រប់គ្រង តែតំបន់ហ្នឹងគេបែងចែកជាភូមិភាគទៀតណាស ហើយមិនដឹង ជាខាងយោធាឬខាងសេដ្ឋកិច្ចទេ ត្បិតអីភារកិច្ចគាត់ ។ ត្បិតអីខ្ញុំអ្នកនៅខាងក្រោមនេះ រៀនពេទ្យមើលអ្នករបួសមើលអ្នកជំងឺចឹងទៅខាងឆ្នបផ្សេងទៅ ខាងខ្ញុំផ្សេងទៅ ទោះបីនៅ ខាងពេទ្យក៏ខ្ញុំមិនសូវ បានរៀនអីច្រើនដែរក្រោយមកខ្ញុំទៅនៅខាងឡូត៍នេសាទ ។

ឈុនលី ៖ ចឹងអ្នកជំងឺហ្នឹងសុទ្ធតែអ្នកតស៊ូ?

សុខុន ៖ សុទ្ធតែអ្នកតស៊ូ ប្រជាជនយើងមានមន្ទីរពេទ្យប្រជាជនផ្សេង មន្ទីរពេទ្យធំៗ ។

ឈុនលី ៖ អាហ្នឹងគេហៅមន្ទីរពេទ្យអីគេ?

សុខុន ៖ អាមួយមន្ទីរពេទ្យតំបន់ ។

ឈុនលី ៖ ចុះខាងអឹនៅ?

សុខុន ៖ ខាងខ្ញុំនៅគេហៅមន្ទីរពេទ្យតំបន់ ពេទ្យតំបន់នេះសំរាប់ខាងយោធា តែខ្ញុំមន្ទីរពេទ្យនេះ សំរាប់ គ្រាន់តែទទួលខាងអន្តភាពរបស់យើងអ្នករបួសអី យកមកមើលផ្សេងៗណាស់ ត្បិតអីនៅតំបន់នោះ មានមន្ទីរពេទ្យគេផ្សេងៗផ្នែកគេផ្សេងៗ មានវះកាត់អីហើយខ្ញុំ ក្រោយមកទៀតទៅនៅខាង ឡូត៍នេសាទ តំបន់គេឡូត៍ធំណាស់ ។

ឈុនលី ៖ ចឹងឆ្នាំ១៩៧៤?

សុខុន ៖ ៧៨ ខ្ញុំទៅនៅឡូត៍ ។

ឈុនលី ៖ ទៅនៅឡូត៍ហ្នឹងធ្វើអីទៅ?

សុខុន ៖ ឡូត៍ហ្នឹងយើងទៅនៅវះត្រីងៀត ម្ហូបអាហារត្រីឆ្អើរសំរាប់ផ្ញើឲ្យកងទ័ព ហើយធ្វើប្រហុក ផ្អកសំ រាប់បំរើប្រជាជន ។

ឈុនលី ៖ ឡូត៍ហ្នឹងនៅឯណាវិញ?

សុខុន ៖ ឡូត៍មានច្រើនតាំងពីឡូត៍១ដល់ឡូត៍១២ ។ ឡូត៍មួយនៅស្ទឹងកូនជ្រៃ ។

ឈុនលី ៖ នៅស្រុកអីគេវិញ?

សុខុន ៖ នៅស្អាង កោះធំ ខេត្តកណ្តាលនៅស្ទឹងកូនជ្រៃ ។

ឈុនលី ៖ ចុះអ៊ំនៅឡូត៍នោះយូរដែរអត់?

សុខុន ៖ ខ្ញុំនៅជិតមួយឆ្នាំដល់ក្រោយមកខ្ញុំទៅនៅភ្នំពេញវិញ នៅខាងការដ្ឋាននៅក្រសួងកសកម្មខាងបើក បរ ។

ឈុនលី ៖ ចឹងអ៊ំចេះបើកបរដែរ?

សុខុន ៖ កាលពីមុនគេឲ្យសិទ្ធិនារីស្មើបុរសគេឲ្យយើងបើកឡានបើអាត្រាក់ ។

ឈុនលី ៖ ចឹងអ៊ំបើកអីគេ?

សុខុន ៖ បើកឡានបើកអាត្រាក់នៅក្នុងមន្ទីរសំរាប់ដឹកប្រេងដឹកអីទៅដាក់នៅតាមមន្ទីរ ។

ឈុនលី ៖ ដឹកពីណាមក?

សុខុន ៖ ដឹកពីភ្នំពេញមក ។

ឈុនលី ៖ ដឹកប្រេងដាក់មន្ទីរហ្នឹងមន្ទីរអីគេ?

សុខុន ៖ មន្ទីរនៅទឹកថ្លា ។

ឈុនលី ៖ ភ្នំពេញតែទៅយកនៅឯណាវិញ?

សុខុន ៖ មន្ទីរយកពីក្រសួងយកពីឃ្លាំងមកវិញ នៅកន្លែងបើកបរមានឃ្លាំងណាស់ ដល់ពេលអស់ យើងទៅយកនៅឃ្លាំងធំ ។ គេបែងចែកតាមសាខាខាងកសិកម្ម គេចែកតាមមូលដ្ឋាន ពេលអស់ទៅយើងមើលថា ភូមិភាគពាយព្យឬភូមិភាគណាចឹង ទៅគេមកបើកប្រេង សំរាប់ចែក គេមានសាខា គេសំរាប់ចែក ។

ឈុនលី ៖ អ៊ំដែលចូលទៅខេត្តផ្សេងៗដែរអត់?

សុខុន ៖ ខ្ញុំអត់ដែលទេនៅតែមន្ទីរ មានតែប្រុសៗដែលទៅ ។

ឈុនលី ៖ មន្ទីរហ្នឹងនៅភ្នំពេញដែរអត់?

សុខុន :	មន្ទីរហ្នឹងនៅភ្នំពេញ

ដឹកពីក្រសួងឡានគេមានមុខសញ្ញាដូចថាមានគេមួយក្រុមដឹកទៅខាងភូមិភាគ ពាយ័ព្យមួយក្រុមដឹកទៅខាងសៀមរាបមួយក្រុម ដឹកទៅខាងខេត្តកណ្តាលអាស្រ័យលើតំរូវការតាមភូមិភាគមួយដែលគេចុះទៅអភិវឌ្ឍន៍ ដូចកន្លែងខ្លះត្រូវការទៅភ្ជួរស្រែតាមកងចល័តតាមតំបន់គេធ្វើស្រែណាស តែប្រេងយើងនៅមន្ទីរយើងសំរាប់តែដឹកសំភារៈ ដឹកអាត្រាក់ចេញតាមច្រកកំពង់សោមអី មកយើងយកប្រាក់ហ្នឹងទៅដាក់នៅក្នុងមន្ទីរក្រសួងគេចែកមក ។ ដូចគេត្រូវការអាត្រាក់ចឹង ប្រេងហ្នឹងយើងចាក់ឲ្យគេ១០០លីត្រ ឬ២០០លីត្រគេដឹកចេញចឹងឯងមានសាខាគេ ។

ឈុនលី :	ចុះក្រោយមកម៉េចទៀត?

សុខុន :	ចេញពីហ្នឹងមកទៅនៅខាងទឹកថ្លាខាងសំណង់ជាមួយកូរេ ។

ឈុនលី :	អាហ្នឹងឆ្នាំណា?

សុខុន :	ឆ្នាំ៧៥ ។ ៧៧ ៧៨ចាប់ផ្តើមសាងសង់រោងចក្រហើយ ។

ឈុនលី :	រោងចក្រអីគេ?

សុខុន :	មុនដំបូងគេតំឡើងរោងចក្រលីង មានរោងច្រកស្ករដែក តំឡើងត្រាក់ទ័រ ដល់ក្រោយមកខ្ញុំរត់ចេញមកដោយសារយួនវាយមក ។

ឈុនលី :	ចឹងធ្វើនៅទីនោះបានប៉ុន្មានឆ្នាំ?

សុខុន :	គិតទៅតាំងពី៧៥ដល់៧៩ កូរេជួយយើងច្រើន ធ្វើរោងចក្រសម្ភោធ ហើយនៅតែថ្ងៃប្រើប្រាស់ហ្នឹងណាស យួនវាដេញយើងដល់តែដេញទៅយើងអត់បានធ្វើទេ ។

ឈុនលី :	ចុះរោងចក្រហ្នឹងធ្វើពីឆ្នាំណា?

សុខុន :	រោងចក្រនោះធ្វើចាប់ពីឆ្នាំ៧៧

សម្ភោធហើយដល់ក្រោយមកយួនចូលមិនដឹងគេយកទៅធ្វើអី ទៀតសម្ភោធថ្ងៃទី១៧ ខែ១២ ខ្ញុំនៅធ្វើការទីនោះ ។

ឈុនលី :	ឆ្នាំណា?

សុខុន :	ឆ្នាំ១៩៧៩ដល់ថ្ងៃ៧មករា ត្រូវរត់ ។

ឈុនលី :	នៅឆ្នាំ៧៧ ៧៨ ៧៩ គេធ្វើរោងចក្រចុះអីនៅឯណា?

សុខុន :	ធ្វើរោងចក្រតម្បាញមានគ្រប់នៅភ្នំពេញ តែក្រសួងខ្ញុំនៅកសិកម្មខ្ញុំត្រូវកសាងជាមួយមិត្តភ័ក្ត បងប្អូន អ្នកដឹកនាំជាមួយអ៊ំៗដើម្បីកសាង ។

ឈុនលី ៖ អ៊ឹណាទៅ?

សុខុន ៖ ដូចអ៊ី ប៉ុល ពតគាត់នៅភ្នំពេញតែការដឹកនាំរបស់គាត់ធ្វើការជាមួយកូរេអ៊ីល្អណាស់ ។

ឈុនលី ៖ ល្អយ៉ាងម៉េចទៅ?

សុខុន ៖ ល្អត្រង់ថាដឹកនាំសំរេចផែនការបានល្អដល់ពេលរោងចក្រជិតដមណើរការយួនដេញ ។

ឈុនលី ៖ ចឹងបានន័យថាក្នុងអំឡុងពេលឆ្នាំ៧៥ហ្នឹងអ៊ីអត់ធ្វើការនៅរោងចក្រនោះទេ ព្រោះទើបតែធ្វើ?

សុខុន ៖ អត់ទេ ដំណើរការទី១ពួកខ្ញុំឡើងមកធ្វើការនៅខាងកសិកម្មហ្នឹងមួយផ្នែកនៅខាងការដ្ឋានមួយ ផ្នែកនៅខាងបើកបរ មួយផ្នែកទៀតនៅខាងកម្មករកសាងរោងចក្រជាមួយភ្ញៀវកូរ៉េដែលគាត់មកធ្វើឲ្យហ្នឹង ហើយគាត់ត្រលប់ទៅវិញគាត់ត្រូវឲ្យយើងប្រើប្រាស់ ហើយដូចកាត់ខ្សែបូរចឹងណាស់ តែអាល្បែងយួននេះ ខ្សែក្បត់វាច្រើនប្រទាក់ប្រទាញចឹង យើងត្រូវរត់ណាស ។

ឈុនលី ៖ ចឹងអ៊ីនៅធ្វើការខាងកសិកម្មដដែល?

សុខុន ៖ ចា៎!

ឈុនលី ៖ ចឹងយើងនៅធ្វើការកសិកម្មដដែលព្រោះអត់ទាន់បានប្រើប្រាស់?

សុខុន ៖ អត់ទាន់ឲ្យប្រើប្រាស់អីគឺពួកខ្ញុំកម្មករទៅធ្វើផ្ទាល់ហ្នឹងណាស់ ។

ឈុនលី ៖ ហ្អស! អ៊ីអ្នកជួយធ្វើចឹង?

សុខុន ៖ ជួយធ្វើណាស់ ដូចថាចាក់គ្រឹះចាក់អីតំឡើងរោងចក្រហ្នឹងអស់ ហើយម៉ាស៊ីនអីដឹកយកមកដាក់អស់ ហើយអត់មានខ្វះអីទៀតទេ ។

ឈុនលី ៖ កម្មកររោងចក្រ ។

សុខុន ៖ កម្មកររោងចក្រកសិកម្មគឺយើងធ្វើដោយដៃ កម្លាំងយុវជនយុវនារីយើងណាស ា

ឈុនលី ៖ ច្រើនអត់កម្មករហ្នឹង?

សុខុន ៖ ច្រើនតែគេបែងចែកជាផ្នែកៗណាស់ អ្នកណាខាងផ្សារៗ អ្នកណាខាងកាត់ដែកៗ ខាងតំឡើងរោងចក្រៗ លាយស៊ីម៉ង់ត៍ រៀបឥដ្ឋការ៉ូ ចាក់គ្រឹះ តំឡើងរោងចក្រដល់ពេលហើយព្រមគ្នា តំឡើងព្រមគ្នាជិតដំណើរការយួនដេញ ។ រោងចក្រនោះធំណាស់ចុះទំរាំតែធ្វើហើយ ។

ឈុនលី ៖ ធ្វើ២ឆ្នាំអ៊ី ។ ចុះកាល៧៩ ពេលចេញមកគេប្រាប់ថាម៉េច? ម៉េចបានមកនៅនេះវិញ?

សុខុន ៖ ចេញមកដោយសារយួនវាដេញមក យើងចេះតែចេញមក ដោយសារកងទ័ពយើង ទប់ទល់មិន ឈ្នះ ចេះតែចេញមកទប់ទល់តែខាងក្នុងចឹងចេះតែចេញមកដើម្បីភៀសខ្លួន ។

ឈុនលី ៖ ចុះគេមានប្រាប់ឲ្យមកតំបន់នេះដែរអត់?

សុខុន ៖ អត់ប្រាប់ទេត្បិតអីយើងរត់មកមានអង្គការដឹកនាំណាស់ ។

ឈុនលី ៖ អ្នកណាខ្លះអ្នកដឹកនាំ?

សុខុន ៖ មានអ្នកណាមានតែអឹខាងលើៗគាត់ដឹកនាំឲ្យយើង ។

ឈុនលី ៖ អឹ ប៉ុល ពត?

សុខុន ៖ ចាស៎ អឹ ប៉ុល ពត អ៊ីមអីហ្នឹងមកគាត់ចេះតែវៃ ប្រជាជនយើងចេះតែរត់មក ។

ឈុនលី ៖ មានអ្នកណាខ្លះទៅ?

សុខុន ៖ អូ! ខ្ញុំស្គាល់មិនអស់ទេ នៅក្រសួងខ្ញុំៗស្គាល់តែ....

ឈុនលី ៖ ចុះនៅក្រសួងកសិកម្មអ្នកណាគេកាន់?

សុខុន ៖ ក្រសួងកសិកម្មដំបូងឈ្មោះ ជ័យ ជ័យ សួត គាត់ស្មើនឹងរដ្ឋមន្ត្រីនៅភ្នំពេញ ហើយក្រោយមក ទៀតមានពូណេង ។

ឈុនលី ៖ ក្រោមគាត់ទៀតអ្វី?

សុខុន ៖ គាត់ប្រធានទី២ ដល់ប្រធានទី២ឈ្មោះ ពូ ណេង ខ្ញុំអត់ដឹងឈ្មោះជីតាគាត់ទេ ហើយមួយទៀតឈ្មោះ ពូវ៉ាត វ៉ាតហ្នឹងបន្ទាប់ទី៣ ។ ក្រោយមកទៀតខ្ញុំរស់នៅជាមួយគាត់ជីវភាពរស់នៅ ហុបចុកអីគ្រប់គ្រាន់បរិបូរណ៍ហូរហៀ ។ ការដឹកនាំរបស់គាត់ល្អគឺសំរេចផែនការបានមួយថ្ងៃបី ពេលកម្មករ កសិករហូប....និយាយរួកកម្មករ កសិករហ្នឹងគាត់ដឹកនាំបានល្អណាស់អត់មានបញ្ហាអីទេទាំងអឹថ្នាក់លើ ទាំងថ្នាក់ក្រោមគាត់ឲ្យជីវភាពរស់នៅល្អទាំងស្បៀងអាហារ ខោអាវស្បៀក ពាក់មានមន្ទីរពេទ្យ ពេលយើងឈឺយើងទៅព្យាបាលអត់មានប្រើមនុស្ស ហើយយកមនុស្សទៅវៃចោលអីអត់ទេ ។

ឈុនលី ៖ ចុះអឹនៅទីនោះមានដែលដឹងថាមានរឿងអត់បាយអីដែរអត់?

សុខុន ៖ អត់បាយអូនឯងដឹងអត់ កន្លែងណាដែលមានការដឹកនាំល្អគឺហូបគ្រប់គ្រាន់ កន្លែងណាដែលហូបមិនគ្រប់គឺវាក្បត់ពីអង្គការដោយសារអី? គាត់និយាយមកតែពីរម៉ាត់ដល់ពេលវាយកមកនិយាយបីបួនម៉ាត់ ចាំមើលអឹអធិប្បាយឲ្យស្តាប់ អឹខាងលើគាត់ប្រាប់មកថាឧទាហរណ៍ៈ សហករណ៍ខ្ញុំមួយធ្វើស្រូវបានពីប្រជាជន១០០០គ្រួសារ ហើយប្រជាជនខ្ញុំត្រូវហូប១០តោន ហើយសហករណ៍ខ្ញុំបានតែ៨តោនអត់គ្រប់ សហករណ៍ខ្ញុំត្រូវយកទៅ

ឧបត្ថម្ភនៅសហករណ៍មួយទៀត ហើយបើនៅសល់ យកទៅឧបត្ថម្ភឲ្យរដ្ឋដឹកចេញទៅលក់នៅក្រៅ ដើម្បីដោះដូរយកសម្ភារៈមកក្នុងវិញ ។ ឧទាហរណ៍ដូចខាងកសិកម្ម ដោះដូរជាឡាន អាត្រាក់ និងអ្វីដែលត្រូវការដើម្បី កសាងប្រទេសតែមួយ ចំណែកទៀតដែលវាមានក្បត់ហ្នឹង ដោយសារដូចថាគាត់ឲ្យហូបមួយថ្ងៃបីពេលតែអាក្បត់ហ្នឹងវា អត់ឲ្យហូបទេ ដល់ពេលអឹគាត់ចុះមកធ្វើទស្សនៈកិច្ចថ្ងៃនេះចឹង ថាឲ្យកាប់ ជ្រូកឬកាប់គោឲ្យគាត់ឃើញមួយថ្ងៃមួយពេល ឬពីរពេលឲ្យគាត់ឃើញ តែដល់ពេលគាត់ត្រលប់ ទៅវិញគេអនុវត្តផ្សេង ហើយកំថាគាត់ហ្នឹងខុសយកមនុស្សទៅវៃចោល គាត់ថាបើខុសយកទៅអប់រំ តែអាខាងក្រោមដែលប្រឆាំងកើតសង្គ្រាមនេះណាស់ ។ វាមកក្លាយថាគាត់ហ្នឹងខុសតិច តួចយកមនុស្សទៅសំលាប់ចោល ។ ពួកអ្នក១៧មេសាដែលនៅជាមួយខ្ញុំមិនដែលមានអ្នកណាម្នាក់យកទៅវៃចោលទេ ខុសតិចតួចគាត់ថាយក ទៅអប់រំសុទ្ធតែមិត្តយើងបងប្អូន យើងខ្មែរដូចគ្នាទេ ។

ឈុនលី : ពួក១៧មេសាអ្នកថ្មី?

សុខុន : អ្នកថ្មី ។

ឈុនលី : ឲ្យតែនៅខាងនេះ?

សុខុន : អ្នកនៅខាងណាក៏ដោយត្រង់គាត់យកទៅវៃចោលខ្ញុំអត់ដឹងទេណា
ព្រោះអីខ្ញុំរស់នៅឃើញថាផ្នែក នយោបាយដឹកនាំរបស់គាត់ល្អ នៅក្រសួងខ្ញុំហូបចុកគ្រប់គ្រាន់មួយថ្ងៃបីពេលមានតែនៅសល់យកទៅឧបត្ថម្ភជូនរដ្ឋទៀត តែឮថាយកមនុស្សទៅវៃចោលអី អត់មានទេឮតែយកមនុស្សទៅ កសាងយកទៅកសាងថាក្លួយឯងធ្វើចេះៗខុស ។

ឈុនលី : ចឹងអឹដែលឮគេនិយាយដែរថាមានគេយកទៅវៃចោល?

សុខុន : ខ្ញុំអត់ដែលឃើញដែរតែឮគេនិយាយៗ អាហ្នឹងកាលខ្ញុំនៅជាមួយគាត់អត់ដែលឮថាយកទៅវៃចោលទេ ។

ឈុនលី : ដល់ពេលអឹអត់ដែលឃើញចឹងអឹជឿអត់?

សុខុន : ខ្ញុំអត់ជឿដែរតែកន្លែងគេជឿមិនជឿ.... ប៉ុន្តែកាលខ្ញុំនៅធ្វើការកសិកម្មគាត់នៅធ្វើរដ្ឋមន្ត្រីនៅភ្នំពេញ ដូចថាមានការឡើងទៅរៀនសូត្រម្តងៗ គាត់ឲ្យយោបល់ឲ្យកសាងធ្វើនេះធ្វើនោះចឹង គាត់ឲ្យយើងមកតែមួយផ្នែកទៀតវាក្បត់វាចង់ដណ្តើមរដ្ឋអំណាចពីភ្នំពេញ តែអាក្បត់ខ្លះវាងាប់ អស់ខ្លះហើយ ។

ឈុនលី ៖ អ្នកណាគេទៅ?

សុខុន ៖ ខ្ញុំមិនដឹងត្បិតអី ខ្ញុំនៅតែក្រសួងខ្ញុំហ្នឹង ការដឹកនាំតាំងពីថ្នាក់លើដល់ក្រោមឃើញថាស្ទៀកពាក់ ក៏គ្រប់គ្រាន់ហូបចុកគ្រប់គ្រាន់ ការងារក៏ឲ្យសំរាកត្រឹមត្រូវតែផ្នែកផ្សេងៗទៀត ខ្ញុំអត់ដឹងត្បិតអីវា មិនមែនក្បត់តែមួយកន្លែងឯណា គាត់និយាយ ភ្នែកគាត់តែពីរការដឹកនាំដូចថាខាងរដ្ឋមន្ត្រីៗបី បួននាក់មានអ្នកដែលនៅក្រោមគាត់ ដែលគាត់ទុកចិត្តក្បត់គាត់ទៀត អ្នកណាដឹងខ្ញុំមិនបានចាប់អារម្មណ៍ដែរ អូនតែការដឹកនាំរបស់គាត់សីលធម៌រស់នៅជីវភាពរស់នៅបានស្អាតស្អំល្អ មនុស្សមិនមានលួចកាប់ចាក់គ្នា ។

ឈុនលី ៖ ចុះពេលនោះដូចនៅធ្វើការចឹងមានអ្នកមានគ្រួសាររៀបការដែរអត់?

សុខុន ៖ មានគ្រួសារពេលហ្នឹងមិនមែនគាត់ចាប់បង្ខំយើងទេ
ដែលចាប់បង្ខំមួយចំនួនដូចថាខ្ញុំជាប្រុស អូន ឯងជាស្រីចឹងគាត់ឲ្យតើងស្នើ ដូចខ្ញុំប្រុសស្រឡាញ់អូនឯង បើអូនឯងព្រមក៏ព្រមទៅ បើមិនព្រមក៏អត់ទៅ ដូចថាចាប់បង្ខំការបួនដប់គូចឹង យើងព្រមព្រៀងគ្នា ហើយអាហ្នឹងខ្ញុំឃើញនៅ ក្រសួងខ្ញុំចឹង ។ ខ្លួនខ្ញុំអញ្ចឹងដែរគេស្នើរខ្ញុំៗអត់ស្រឡាញ់ខ្ញុំអត់យក ។

ឈុនលី ៖ ឆ្នាំណាដែលគេស្នើអ៊ឺ?

សុខុន ៖ ស្នើខ្ញុំតាំងពី ៧៦ ៧៧ ៧៨ ៧៩ ខ្ញុំអត់យកដោយសារអី ដោយសារខ្ញុំនៅក្មេងស្រលាញ់ការងារខំកសាងខ្លួនអាហ្នឹង ខ្ញុំប្រកែកបានដែរ តើមានទៅបង្ខំថាអ្នកឯងត្រូវការជាមួយអ្នកនេះអីអត់ទេ អាហ្នឹងខ្លួនខ្ញុំចឹងហើយ ។ អ្នកផ្សេងទៀតក៏គេស្ម័គ្រចិត្តដែរ គេទាក់ទងស្រឡាញ់គ្នាចឹង គេស្នើសុំទៅអាហ្នឹងខ្ញុំនិយាយនៅខាងក្រសួងខ្ញុំ ក្រសួងកសិកម្មមួយ គាត់រដ្ឋមន្ត្រីធំណាស់ណាអូន ។

ឈុនលី ៖ ចាស៎ ព្រោះសម័យនោះយើងពឹងលើកសិកម្ម ។

សុខុន ៖ ចាស៎ ខ្ញុំឃើញចឹង ។

ឈុនលី ៖ ចុះដូចអ៊ឹកម្មករចឹងមានកម្មករគេដែរអ្ហី?

សុខុន ៖ មាន មានកងតូច កងធំ កងវរៈចឹងណាស ខាងខ្ញុំមានរដ្ឋមន្ត្រីចឹង មានម្នាក់ទៀតពីក្រសួងគាត់ក្តាប់ផ្ទាល់ ។

ឈុនលី ៖ ឈ្មោះអីគេទៅអ៊ឹចាំទេ?

សុខុន ៖ ឈ្មោះបង លី ។

ឈុនលី ៖ គាត់អ្នកកាន់ក្រុមអ៊ឹ?

សុខុន ៖ អត់ទេ គាត់កាន់រួមមួយផ្នែកកសិកម្មក្នុងរោងចក្រណាស់

ឈុនលី ៖ ចាស៎

សុខុន ៖ អ្នកក្តាប់រួមមានអ៊ឹបីនាក់ខាងលើ ។

ឈុនលី ៖ ចុះអ៊ឹ ប៉ុល ពត?

សុខុន ៖ អ៊ឹ ប៉ុល ពត គាត់រដ្ឋមន្ត្រីធំជាងគេមួយប្រទេស ។

ឈុនលី ៖ ចុះបីនាក់ហ្នឹងអ្នកណាគេ?

សុខុន ៖ បីនាក់ហ្នឹងដូចខ្ញុំរៀបរាប់ខាងលើ អាហ្នឹងផ្នែកដឹកនាំ ហើយអ្នកខាងក្រោមទៀតមាន បង លី គាត់សព្វថ្ងៃនៅកំពង់ឆ្នាំងមិនដឹងទេ គាត់ដឹកនាំបានល្អណាស់មហាជនស្រលាញ់ គាត់ធ្វើការត្រឹមត្រូវ ។ បើដូចខ្ញុំនៅធ្វើការភ្នំពេញនេះ មានការខុសឆ្គងអីគាត់អប់រំ សាមគ្គី ។

ឈុនលី ៖ ចឹងពេលដែលចេញមកហ្នឹងគេអត់មានប្រាប់ថាទៅណាទៅណីអីទេ?

សុខុន ៖ ជម្លៀសចេញយើងចេះតែរត់ចេញមកបើគេដេញ យើងរត់ចេញតាមអង្គភាពមក ។

ឈុនលី ៖ ច្រើននាក់ទេ?

សុខុន ៖ រាប់ម៉ឺនរាប់សែននាក់ ។

ឈុនលី ៖ ចឹងមិនស្អេកស្កះពេញហ្នឹងហើយ?

សុខុន ៖ ហួសៗឡានក៏ឡាន ម៉ូតូក៏ម៉ូតូ បើកុំតែមានកងទ័ពទប់ទល់ជាមួយពួកយួនឈ្នះម្លេះចូលទៅថៃ ហើយរត់ទៅថៃដោយសារមានការតស៊ូហ្នឹងឯង ស្មានតែអ្នកទាំងអស់គ្នាបើគ្មានខ្មែរក្រហមស្មាន តែបានចូលស្រុកនៅស្រួលអ្វីៗមិនស្រួលទេ ។ តែនេះការចូលមកក៏ដូចជារំដោះកន្លែងណា ដែលមានការកាប់សម្លាប់ខ្លះដែរ ។

ឈុនលី ៖ ចាស៎

សុខុន ៖ ចំណែកខាងក្រសួងខ្ញុំអីចឹង គឺការដឹកនាំ រត់មកចឹងគាត់តស៊ូតាំងពីនៅតាមព្រៃស្ងាប់ខ្លះ យើងរត់មកដាច់ស្បៀងខ្លះ ទំរាំអង្គការយើងដឹកស្បៀងអីមកចឹង គាត់មិនអាចមើលឃើញទាំងអស់ទេ ។ ចឹងបានថាមាត់និងធ្មេញយើងនៅតែទន្ទិចគ្នាខាំអណ្តាត ចុះទំរាំតែគាត់អ្នកដឹកនាំប្រទេសមកផ្គាប់ចិត្តមនុស្សលោកម៉េចនឹងត្រូវ យើងនិយាយចឹង ថាល្អអាគេនោះចង់ក្បត់ក៏ក្បត់ទៅ ។

ឈុនលី ៖ ស្រេចលើការគិតរបស់គេ ។

សុខុន ៖ ស្រេចលើការគិតបស់គេ

បើយើងចេះស្រលាញ់គ្នាក៏យួនមិនបានចូលស្រុកប្រជាជនរស់នៅបាន

សុខសាន្តដំណើរការរោងចក្រអីកើតទាំងអស់ ។ អូនឯងគិតមើលនៅភ្នំពេញក្រណាត់បើកឲ្យពួកកង ចល័តកងទ័ពអីសុទ្ធតែល្អៗ តើមូលហេតុអីពួកក្បត់វាយកទឹកអាស៊ិតទៅចាក់ទាំងឃ្លាំងៗ ។

ឈុនលី : ម៉េចបានគេចាក់ចឹង?

សុខុន : វាចាក់មិនឲ្យកងចល័តស្លៀកពាក់ ហើយបន្ទុចថាអង្គការយើងហ្នឹង មិនឲ្យប្រជាជនស្លៀកពាក់ខ្វះខាត ការពិតទៅនៅភ្នំពេញ គាត់គិតណាស់ គិតថាធ្វើម៉េចយើងនៅភ្នំពេញស្លៀកពាក់មិនបានស្អាតក៏ហីទៅចុះធ្វើម៉េចឲ្យគ្នាអ្នកខាងកសិកម្មផលិតស្រូវស្លូង ដកទ័ពដែលការពារឲ្យស្លៀកស្អាត ចុះតែតាមពិតអត់គ្រប់គ្រាន់ទេដោយសារអី? ដោយសារការគ្រប់គ្រងតាមអង្គភាពមួយៗវាអញ្ចឹង ។ អង្គភាពខ្លះយកកូនក្មេងទៅដឹកនាំដោយសារអី? ដោយសារយកអ្នកចេះដឹង មានខ្សែមិនមានខ្សែ ចឹងយកកូនក្មេងមកដឹកនាំក៏វាមិនត្រឹមត្រូវ តែកន្លែងគាត់នេះនៅក្រសួងខ្ញុំរស់នៅ គ្មានបញ្ហាទេ ដល់ក្រោយមកទៀត ខ្ញុំក៏អត់ដឹងទេ ។ តែនៅភ្នំពេញក្រសួងខ្លះល្អៗអ្នកណាចង់បាន មុខមាត់គេក្បត់ពីគាត់ទៅ ។

ឈុនលី : ដើម្បីផលប្រយោជន៍ ។

សុខុន : ចាស៎ ផលប្រយោជន៍គេចង់ផ្តួលរំលំ ដល់ចឹងទៅខ្ញុំមិនដឹងដែរខ្ញុំដឹងតែខាងក្រសួងខ្ញុំណាស់អារឿង ដឹកនាំនៅក្នុងក្រសួងវាចេះតែមានការខ្វះខាត ហើយសូម្បីតែម៉ែឪយើងក៏មានស្តីប្រដៅដែរ ចុះទំរាំ គាត់ដឹកនាំទូទាំងប្រទេស ។

ឈុនលី : ចុះពេលមកដល់ភ្លាមនៅឯណាទៅ?

សុខុន : នៅហ្នឹងនៅតាមព្រំដែនទៅ ។

ឈុនលី : នៅភូមិណាទៅ?

សុខុន : អត់មានភូមិទេ នៅតាមអង្គភាពចឹង អង្គភាពនារីចឹងនៅមួយកងវរៈចឹងៗ ធ្វើផ្ទះនៅទៅដឹកជញ្ជូនទៅអត់ទាន់មានផ្ទះទេ ដល់ពេលស្រុកយើងសុខស្រួល ចឹងបានមានផ្ទះនៅតាមព្រំដែន ។

ឈុនលី : ចុះតំបន់នេះគេហៅតំបន់អីទៅ?

សុខុន : អានេះគេហៅតំបន់ព្រមដែនពីមុនអត់មានអីទេ ទើបតែឥឡូវវាកើតជាតំបន់កើតជាស្រុកកើតជាឃុំ ។

ឈុនលី : តំបន់ព្រំដែន?

សុខុន : ចាស៎ តំបន់ព្រំដែន ។

ឈុនលី ៖ អាហ្នឹងអត់មានបែងចែកតមបន់លេខប៉ុន្មានអីអត់ទេ?

សុខុន ៖ អត់ទេ ពីមុនវាគ្រាន់តែមានអគ្គភាពយោធា អគ្គភាពដឹកជញ្ជូន អគ្គភាពពេទ្យចឹង ។

ឈុនលី ៖ ចឹងឲ្យតែនារីគេឲ្យទៅដឹកជញ្ជូន?

សុខុន ៖ យើងខ្លះដឹកជញ្ជូន ខ្លះមានគ្រូសារគាត់នៅក្រោយចឹងទៅ ។

ឈុនលី ៖ ចឹងគាត់អត់ទៅធ្វើទ័ពទៀតទេចឹង?

សុខុន ៖ នារីកងដឹកជញ្ជូនធ្វើទ័ពអីទៀត បើដឹកជញ្ជូនឲ្យទ័ពដូចតែធ្វើទ័ពដែរហ្នឹងតែអាមួយអគ្គភាព ដឹកជញ្ជូន ហើយមួយទៀត អគ្គភាពការពារខាងមុខ ។

ឈុនលី ៖ អគ្គភាពការពារខាងមុខ ។

សុខុន ៖ ម៉េចគេហៅថាសមរភូមិនោះ ។

ឈុនលី ៖ ចឹងមានពេទ្យដែរ?

សុខុន ៖ ទៅអត់អីនោះ ពេទ្យវះកាត់ ពេទ្យប្រជាជន ក្រោយមកទៀតបានមានពេទ្យកាកបាទ ។

ឈុនលី ៖ ចឹងកាលមកដល់ភ្លាមហ្នឹងយួនដេញមកដល់ណា?

សុខុន ៖ យួនដេញមកដល់ហ្នឹងយើងរត់ទៅថៃទៅហើយកងទ័ពយើងការពារទៅ ។

ឈុនលី ៖ កាលនោះឆ្នាំចិតប៉ុន្មាន?

សុខុន ៖ ៧៩ ៨០ អីហ្នឹង ។

ឈុនលី ៖ ចឹងវៀតណាមចូលមកដល់នេះដែរ?

សុខុន ៖ និយាយចូលមិនដល់ម៉េច ព្រោះតែចូលមកហ្នឹងហើយ បានជាខ្មែរយើងរត់ទៅដល់ថៃ តែយោធា យើងនៅការពាររហូតដឹកស្បៀងដឹកអីមក ។

ឈុនលី ៖ ចុះពេលអ៊ំមកដល់ហ្នឹងចូលអគ្គភាពអីគេដែរ?

សុខុន ៖ ខ្ញុំខាងដឹកជញ្ជូន ។

ឈុនលី ៖ មានស្បៀងមានអាវុធអីចឹង?

សុខុន ៖ ចុះទៅខ្លះអីដឹងមកទាំងឡានៗដឹកទាំងយន្តហោះទៀតខ្លះអី ។

ឈុនលី ៖ អ៊ំបើកឡានដឹកទៀត?

សុខុន ៖ ទេ ដល់ពេលនោះយោធាគេសុទ្ធតែប្រុសៗគេធ្វើរជើង យើងទៅបើកបរអីនៅក្នុង សង្គ្រាមនោះ យើងគ្រាន់តែថា នៅអគ្គភាពដឹកជញ្ជូនយើងដឹកស្បៀងដឹកអី ទៅដាក់នៅ ឃ្លាំងសំរាប់តែគេត្រូវការគេទៅយកទៅ ។ នារីក៏កាន់អាវុធដែរ នៅខាងមុខនោះត្រូវវ៉ៃៗ ដូចតែគ្នាហ្នឹង ។

ឈុនលី ៖ ចុះអ៊ីទៅនៅជំរុំដែរមែនអត់?

សុខុន ៖ ខ្ញុំទៅតាដ៉ុកចេញពីតាដ៉ុកមកទៅនៅ៥-៨៥ ។

ឈុនលី ៖ ទៅជំរុំហ្នឹងឆ្នាំណា?

សុខុន ៖ ឆ្នាំ៨៤ ៨៥ ។

ឈុនលី ៖ ចឹងខ្វង់៨២ ៨៣កំពុងតែច្បាំងហើយ?

សុខុន ៖ នៅទីនេះអត់អីទេគេច្បាំងគ្នានៅមុខ ។

ឈុនលី ៖ ចឹងកាលនោះមានព្រៃដែរអត់?

សុខុន ៖ ព្រៃ ព្រៃធំៗដល់ពេលយើងមកនៅយើងកាប់ឆ្ការវាធ្វើស្រែបាន ។

ឈុនលី ៖ ចឹងនៅទីនេះសុទ្ធតែព្រៃ?

សុខុន ៖ ព្រៃដែរតើអូន យើងនៅជួរមាត់អូរទេដល់ពេលឆ្នាំ៩០ បានយើងមកនៅនេះបានយួនដេញ ។

ឈុនលី ៖ ចុះដល់ពេលមកដំបូងមានមីននៅទីនេះដែរ?

សុខុន ៖ មីន1អត់មានទេពីដំបូង ។

ឈុនលី ៖ ពេលណាបានមាន?

សុខុន ៖ ពេលសង្គ្រាមជាមួយវៀតណាម ។

ឈុនលី ៖ អ្នកណាអ្នកដាក់មីន?

សុខុន ៖ ខាងយើងក៏ដាក់ការពារខាងយើងក៏ដាក់ការពារសំខាន់យួនវាដាក់ច្រើនហ្នឹងឯង ។

ឈុនលី ៖ យួនដាក់ច្រើនជាងយើង?

សុខុន ៖ ហ្នឹស1យួនវាដាក់ទាំងខ្សែៗ ។

ឈុនលី ៖ ចុះនៅតំបន់នេះក្រៅពីទាហានខ្មែរក្រហមមានទាហានណាទៀត?

សុខុន ៖ មានទាហានយួន មានទាហានខាងសម្តេច ហ៊ុន សែន ពួកក-៥អីនេះតែដល់យើងត្រូវគ្នាប្រយុទ្ធ ចូលគ្នាអស់ ។ ទាហានមានប៉ាវ៉ាដែរ ខ្ញុំមិនសូវដឹងទេដឹងតែខាងខ្ញុំ ។

ឈុនលី ៖ កាលនោះអ្នកណាគេដឹកនាំពេលមកដក់នេះភ្លាម?

សុខុន ៖ តំបន់នេះវាមានតាមថ្នាក់ខ្លះស្លាប់អស់ ហើយអ្នកដឹកនាំធំៗមានតែ តា ភាព កងពល ។

ឈុនលី ៖ សុខ ភាព?

សុខុន ៖ ចាស៎ ខ្លះទៀតក៏គាត់ស្លាប់អស់ទៅ ។

ឈុនលី ៖ កាលនោះកងពលមានលេខទេអី?

សុខុន ៖ កងពលមានលេខតែខ្ញុំមិនសូវដឹងទេព្រោះខាងយោធា ខ្ញុំដឹងតែខាងដឹកជញ្ជូន ដឹកជញ្ជូនវា តាមវីរៈ ទេ វរៈ១ វរៈ២ ចឹងទៅណាស់ ។

ឈុនលី ៖ ចុះអ្នកណាគេកាន់វរៈអឹ?

សុខុន ៖ វរៈខ្ញុំមានតែ យាយ រ៉ុម តា ហន ដល់ហើយគេបែកចេញចេះទៅបែកគ្នាអស់មាន បង ធីខាង វរៈសេនាធំ ។

ឈុនលី ៖ ស្រី ឬប្រុសធីហ្នឹង?

សុខុន ៖ ស្រី គាត់នៅអង្គភាពហ្នឹងដឹកចេញមកខាងភស្តុភារស់ដល់ក្រោយមកគាត់ស្លាប់អស់ ។

ឈុនលី ៖ ចុះដល់ពេលច្បាំងគ្នាហើយគេដាក់មីនហើយនៅពេលយើងទៅព្រំដែនហ្នឹងអឹ?

សុខុន ៖ កាលពួកខ្ញុំចេញទៅឃួនវាដាក់មីនតាមមាត់អូរនេះ ។

ឈុនលី ៖ ៨៤គិតទៅ?

សុខុន ៖ ៨៥ចេញមកវិញឆ្នាំ៩០ ។

ឈុនលី ៖ ទៅថៃទៅនៅជំរុំតាង៉ុក?

សុខុន ៖ នៅជំរុំក្អុក ជំរុំ៨៥....

ឈុនលី ៖ តាង៉ុក ឬក្អុក?

សុខុន ៖ តាង៉ុក ។

ឈុនលី ៖ ហើយក្រោយមកបានមកនៅថ-៨៥?

សុខុន ៖ អត់ថ-៨៥ ទេជំរុំ៨៥ ។

ឈុនលី ៖ ម៉េចបានជំរុំពីរហ្នឹងខុសគ្នា?

សុខុន ៖ ជំរុំមួយជាជំរុំកាកបាទ ។

ឈុនលី ៖ អាមួយណាទៅជាជំរុំកាកបាទ?

សុខុន ៖ មួយនៅ តា ង៉ុក ។

ឈុនលី ៖ អាហ្នឹងម៉េចទៅអឹអ្នកណាខ្លះអាចទៅជំរុំហ្នឹង?

សុខុន ៖ ប្រជាជនទៅចំរុះ...

ឈុនលី ៖ ដូចខាង៨៥ហ្នឹងដែរ?

សុខុន ៖ ខាង៨៥នេះជាអង្គភាពខាងទ័ព ខាងខ្មែរក្រហមខាងពេទ្យ ប្រជាជននៅខាងគ្រួសារ យោធា ។

ឈុនលី ៖ ភាគច្រើនយោធានៅ?

សុខុន ៖ ចាស៎ យោធា ហើយនៅតាផ្ទុំកនោះជុំរុំកាកបាទសំរាប់ប្រជាជននៅ ប្រជាជនយើងទៅ នៅហ្នឹង អាហ្នឹងខាងប្រជាជន ។

ឈុនលី ៖ ហើយអ៊ំនៅជំរុំបានប៉ុន្មានឆ្នាំ?

សុខុន ៖ ខ្ញុំនៅតាផ្ទុំកអត់បានមួយឆ្នាំទេ ខ្ញុំរត់មកនៅជំរុំ៨៥ នេះ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ នៅ បាន៥ឆ្នាំដល់ឆ្នាំ៩០ចូលមកនៅទឹកដីមាតុភូមិខ្មែរវិញ ។

ឈុនលី ៖ ចុះនៅក្នុងជំរុំហ្នឹងមានធ្វើការងារអីខ្លះទៅរាល់ថ្ងៃ?

សុខុន ៖ ធ្វើការសមរាប់សមរភូមិក្រោយធ្វើខាងពេទ្យហ្នឹងឯង ។

ឈុនលី ៖ ចឹងបានន័យថាពេលយោធាមកច្បាំងមានរបួសចឹងបញ្ជូនយកទៅព្យាបាល?

សុខុន ៖ ចាស៎ ប្រជាជនក៏មកនៅហ្នឹងក្រុមគ្រួសារយោធាអី ។

ឈុនលី ៖ ពិបាកដែរអត់អ៊ំ?

សុខុន ៖ អត់មានពិបាកអីទេ អន្តហូបចុកទាំងបាវៗ ។

ឈុនលី ៖ ខាងណាអ្នកជួយស្បៀងហ្នឹង? ខាងកាកបាទក្រហមឬខាងខ្មែរក្រហម?

សុខុន ៖ ខាងកាកបាទគេជួយខ្លះហើយខាងបរទេសគេជួយខ្លះ....

ឈុនលី ៖ ខាងយើងខ្លះដែរ?

សុខុន ៖ ខាងយើងមានអីមានតែខាងបរទេសហ្នឹងឯង ។ កាកបាទជួយប្រជាជន ខាងបរទេសជួយ យើង ។

ឈុនលី ៖ បរទេសហ្នឹងមានប្រទេសណាខ្លះទៅ?

សុខុន ៖ ខ្ញុំមិនសូវដឹងដែរ
ប្រទេសចិនទេដឹងខាងនោះខាងគាត់ដែរហើយប្រទេសប៉ុន្មានដែលគេស្នេហាជាតិ
ខាងខ្មែរក្រហមហ្នឹងគេជួយខ្លះទៀត
ខាងថៃអីគេជួយយើងឲ្យនៅសុខសប្បាយគេខាងទទួលយើង
ណាស1 ពេលភៀសខ្លួនទៅនៅប្រទេសគាត់ហ្នឹង ។ ការហូបចុកមិនមានបញ្ហាអីទេ
ឈឺថ្កាត់ទៅ ពេទ្យ ព្រោះពេទ្យហ្នឹងយកទៅជំរុំអស់ពីជំរុំទៅខាវអ៊ីដាងអីទៀត....

ឈុនលី ៖ ខាវអ៊ីដាងនៅឯណាទៅ?

សុខុន ៖ ខាវអ៊ីដាងនៅថៃកាំពុធ....ពួកជំរុំហ្នឹង ខាងកាកបាទជួយមិនខ្វះអីស៊ី ប្រជាជនឯក្នុងមកដឹក តែអន្តរពី នេះទៅរាប់ពាន់រាប់ម៉ឺននាក់ចេញចូល... ។

ឈុនលី ៖ គេលក់ដែរអត់?

សុខុន ៖ លក់អីកាកបាទគេឲ្យមក យើងនៅតាមព្រំដែន រង់ចាំប្រជាជនពីក្នុងមកមានគោមានអីដឹកឲ្យគាត់យកទៅក្នុងវិញទៅ ។

ឈុនលី ៖ យើងអ្នកជួយគាត់ខាងក្នុងវិញ?

សុខុន ៖ ចាំ! យើងខាងក្នុងមានប៉ុន្មានរាយការណ៍ប្រាប់គាត់ទៅ គាត់ខបត្តម្ភអង្ករដឹកទៅឲ្យតែយកទៅរួចខុះអី នោះ ។

ឈុនលី ៖ មានអង្ករមានត្រីខ?

សុខុន ៖ អូស!ទៅខុះអីបើនិយាយពីស្បៀងមានមួយចប់តាំងពីថ្នាំពេទ្យអីមិន ខុះទេដូចតែគេយើងនៅឯក្នុងដែរ ។ នៅក្នុងគ្រាន់យើងរហេមរហាមអត់មានអីស៊ី កាលជិនាន់នោះអត់មានខុះអីស៊ីទេឲ្យតែ អ្នកឯងប៊ិនហូបម្នាក់ៗធាត់ដូចជ្រូក ។

ឈុនលី ៖ ចុះដល់ពេលចូលមកទឹកដីយើងវិញឆ្នាំ៩០ម៉េចដែរអ៊ឺ?

សុខុន ៖ អាហ្នឹងដល់ពេលអង្គការយើងចប់សង្គ្រាមទៅត្រូវគ្នាទៅ....

ឈុនលី ៖ ៩០អត់ទាន់ត្រូវគ្នាទេអ្ហ៎?

សុខុន ៖ ត្រូវហើយយើងចូលមក....

ឈុនលី ៖ នៅនេះផ្តាច់ខ្លួនឆ្នាំណាដែរ?

សុខុន ៖ អានេះនៅទីនេះ៩៧បានធ្វើសមាហរណ៍កម្ម ។

ឈុនលី ៖ ចុះឆ្នាំ៩០ ៩១ ៩២ហ្នឹងធ្វើអីទៅអ៊ឺ?

សុខុន ៖ អាហ្នឹងយួនចេញទៅ យើងទៅប្រចាំការនៅសមរភូមិមុខហ្នឹង អត់សូវមានវ៉ៃគ្នាទេ វៀតណាម ចេញទៅខាងក្នុងៗសុទ្ធតែបានរំដោះដោយសារបង្ហូរឈាមហ្នឹងទេ ។

ឈុនលី ៖ តំបន់ជួរមុខហ្នឹងបើដូចឥឡូវស្ថិតនៅក្នុងស្រុកអីគេ?

សុខុន ៖ ហួស1អារឿងសមរភូមិហ្នឹង វាចែកចាយគ្នាអស់ហើយ ឥឡូវនេះចែកទៅតាមខេត្តដូចនៅបន្ទាយមានជ័យចឹង វាចែកជាប៉ុន្មានស្រុកមានប៉ុន្មានឃុំចឹង ដល់ប្រជាប់ចូលគ្នាទឹកដីហ្នឹងប្រជាជនខាងក្នុងក៏បានយើងក៏បានគេចែកគ្នាណាស ។ ចែកព្រំប្រទល់គ្នាដូចថា ឥឡូវព្រំខាងសំពៅលូន បាត់ដំបងត្រឹមណាខាងបន្ទាយមានជ័យត្រឹមណា ហើយអង្គភាពហ្នឹងចែកទៅតែអាប្រជាជនមកពី ក្នុងហ្នឹងអាងវ៉ាងណាស់ ណាម៉ោចាប់បានតិចតួចហ្នឹង លក់ទៅវិញអស់ទៅវាចឹងឯង ។

ឈុនលី ៖ បើយើងនៅទីនេះចាប់បានយើងនៅ?

សុខុន ៖ យើងនេះយើងចាប់បានយើងនៅ ។

ឈុនលី ៖ ចឹងពេលយើងមកវិញយើងទៅនៅធម្មតា តែអត់ទាន់ចប់សង្គ្រាមទេអ្ហីអ៊ឺ? វៀតណាមចេញទៅ ឆ្នាំណាទៅ?

សុខុន ៖ ចេញទៅអត់មានអីទេយើងរស់នៅ....

ឈុនលី ៖ វៀតណាមចេញឆ្នាំ៩០ ឬ៩១ ៩២?

សុខុន ៖ ខ្ញុំចូលមកឆ្នាំ៩០ ហើយគេសមាហារណ៍នៅឆ្នាំ១៩៩៧ ពេលវៀតណាមចេញទៅមិនដឹងឆ្នាំណាទេ ខ្ញុំក្មេងដែរដល់ពេលសមាហារណកម្មចឹង ទៅយើងរកដីធ្វើស្រែចំការ ដល់ពេលរដ្ឋខបក្ខម្ខះចឹង យើងធ្វើបានភោគផលធ្វើស្រែធ្វើចំការយើងបានហូបទៅ ។

ឈុនលី ៖ ចុះខ្វង់ឆ្នាំ៩២ ៩៣យើងនៅទទួលស្សៀងទៀត?

សុខុន ៖ នៅ...ទេឈប់ហើយ៩១ ៩២នៅតែអន្តការគេជួយតិចតួច ។

ឈុនលី ៖ ចឹងពេលមកដល់ភ្លាមហ្នឹងគេចែកស្រែចែកអីឲ្យ ។

សុខុន ៖ ចាស៎ ចែកដី ។

ឈុនលី ៖ ហើយមានមីនដែរ?

សុខុន ៖ មានមីនយើងដោះទៅ ។

ឈុនលី ៖ ដោះខ្លួនឯង?

សុខុន ៖ ដោះខ្លួនឯងទៅចាំអ្នកណាគេដោះឲ្យ ។

ឈុនលី ៖ ដោះបានប៉ុណ្ណាយកប៉ុណ្ណឹង?

សុខុន ៖ យើងដោះកាប់មើលបន្តិចដល់ពេលមានច្រើន យើងកាប់ច្រើនទៅវាមានតំបន់វាតំបន់មានមីន តំបន់អត់មីនយើងចាប់បានចឹង ទៅអ្នកនៅមុខៗអ្នកនៅក្រោយចាប់បានយើងបន្តបង្កើនផលទៅ ផលទៅណាសផ្លាស់ប្តូរគ្នាទៅ ។

ឈុនលី ៖ ចាស1ចុះដូចគ្រួសារអ៊ីផ្ទាល់ចឹងមកពីថៃភ្លាមនៅឯណាទៅ?

សុខុន ៖ នៅមាត់អូរនៅនឹង
ដំរួចហើយយើងធ្វើកូនផ្ទះនៅសិនទៅដល់ពេលយើងមានកន្លែងធំហើយបានអារឈើអាអីលើកផ្ទះ ។

ឈុនលី ៖ អ៊ីមានគ្រួសារឆ្នាំណាដែរ?

សុខុន ៖ ខ្ញុំមានគ្រួសារឆ្នាំ១៩៨១ ។

ឈុនលី ៖ ៨១ នៅហ្នឹង? អត់ទាន់ទៅថៃទេចឹង?

សុខុន ៖ អត់ទេខ្ញុំរៀបចំការនៅហ្នឹង ។

ឈុនលី ៖ ចុះគ្រួសារអ៊ំធ្វើអី?

សុខុន ៖ គ្រួសារខ្ញុំធ្វើពេទ្យ...

ឈុនលី ៖ ហួស1ព្រោះអគ្គភាពពេទ្យ ហើយអ៊ំនៅខាងដឹកជញ្ជូន?

សុខុន ៖ ចាស៎ ដល់ពេលគាត់ដណ្តឹងខ្ញុំ ខ្ញុំមកនៅខាងអគ្គភាពពេទ្យដែរ ។

ឈុនលី ៖ ចុះកាលរឹកបោះឆ្នោតដូចយើងនៅទីនេះ មានសង្គ្រាមមានអីដែរ អត់បោះឆ្នោតឆ្នាំ៩៣ ហ្នឹង?

សុខុន ៖ អត់មានទេ ។

ឈុនលី ៖ កាលហ្នឹងវៀតណាមចេញទៅអស់យើងបោះឆ្នោតធម្មតា?

សុខុន ៖ ធម្មតាមានភូមិ ឃុំគេចែកជាភូមិជាឃុំចឹងទៅកាលសមាហរណកម្ម មុនដំបូងសម្តេចរណរិទ្ធគាត់មកក្រោយមកសម្តេច ហ៊ុន សែន មកធ្វើសាលារៀន ។

ឈុនលី ៖ កៅប៉ុន្មានអ៊ំ?

សុខុន ៖ កាលនោះដូច៩៧ ៩៨ សម្តេចរាណរិទ្ធមកហើយបានសម្តេច ហ៊ុន សែន មកតាមក្រោយមួយវគ្គៗ ។

ឈុនលី ៖ សមាហរណកម្មឆ្នាំណា?

សុខុន ៖ ៩៧ ចឹងហើយ ។

ឈុនលី ៖ ស្ថានភាពពេលហ្នឹងម៉េចទៅអាពេលសមាហរណកម្ម?

សុខុន ៖ អត់មានអីទេ រួចទៅយើងសាមគ្គីគ្នាទៅ ពីក្រៅទៅក្នុងពីក្នុងទៅក្រៅទៅ ប្រជាជនពីក្នុងមករស់នៅរាប់ម៉ឺននាក់បងប្អូនយើងទាក់ទងគ្នា ខ្ញុំនៅចឹងបងប្អូនខ្ញុំមករកយើងឯណោះទៅឯណោះទៅមានទៅអី សុទ្ធតែខ្មែរគ្នាឯងហ្នឹង ។

ឈុនលី ៖ ចុះក្រោយសមាហរណកម្មអ៊ំប្រកបរបរអីគេ?

សុខុន ៖ ធ្វើស្រែតិចតួចធ្វើចំការតិចតួច...

ឈុនលី ៖ អាដីដែលយើងរុករកបានហ្នឹង?

សុខុន ៖ ចាស1ដីដែលយើងកាន់កាប់បាន
ប្រជាជនច្រើនដីតិចណាស1មិនដូចកន្លែងខាងត្បូងៗគេផ្សេងដី ម្នាក់ៗរាប់រយហិចតា ។

ឈុនលី ៖ ត្បូងណាទៅ?

សុខុន ៖ នៅខាងសាមគ្គី ខេត្តបាត់ដំបងនៅខាងសំពៅលូន ។

ឈុនលី ៖ ដោយសារប្រជាជនគេតិចចឹង?

សុខុន ៖ ប្រជាជនគេដីទូលាយបើខ្ញុំនេះដីតូចប្រជាជនច្រើនច្រៀកបានម្នាក់បន្តិច ។ ខ្ញុំមានដីចំការ៨ វ៉ែហើយ ដីស្រែអី ។

ឈុនលី ៖ នៅឯណាទៅ?

សុខុន ៖ នៅក្រោយអន់តែនប្រហែលបីគីឡូ ។

ឈុនលី ៖ អឹថាពេលយើងមកនៅភ្ជាមនៅម្តុំមាត់អូរ? ចឹងយើងចាប់ដីកន្លែងណាទៅ?

សុខុន ៖ មាត់អូរហ្នឹងដូចថាយើងមកនៅម្នាក់ចែកដីនៅម្តុំៗចឹង ទៅត្បិតអីបើយើងដើរទៅខ្លាចវាប៉ះមីនប៉ះអី ដល់ពេលយើងរាវមីនរកដីនៅបានធំ ហើយយើងក៏ធ្វើផ្ទះនៅទៅ ហើយយើងឆ្មៀតទៅរកដីចំការខ្លះទៅដីចំការហ្នឹងខ្លះទៅមានមីនខ្លះទៅអត់មានមីន ដល់យើងឃើញចឹងយើងដោះទៅ ។

ឈុនលី ៖ ចុះអឹដល់ពេលសមាហរណកម្មចឹងយើងរស់នៅប្រកបរបរខ្លួនឯងអីចឹង...

សុខុន ៖ ពេលហ្នឹងរដ្ឋយើងបើករបបឲ្យហូប ដល់ពេលយើងឆ្មៀតពេលហ្នឹងទៅរកអីផ្សេងទៅបានមកយើងទុកហូបខ្លះលក់ខ្លះទៅ ដល់ពេលយើងរីងដៃរីងជើង គាត់ព្រលែងយើងឲ្យមានចំការអីចឹងហើយគាត់ មានអីឧបត្ថម្ភយើងទៀត យើងដោះស្រាយជីវភាពខ្លួនយើងតាមគ្រួសារទៅ តែបើគ្រួសារយើងធ្វើ ការនៅអង្គភាពពេទ្យហ្នឹង ដូនកាលបើកប្រាក់ខែបើកអីឲ្យមកចឹងទៅ ។

ឈុនលី ៖ ចុះក្រោយមកដល់ចូលគ្នាគាត់ក៏ឈប់ធ្វើពេទ្យរស់នៅធម្មតាដូចប្រជាជន?

សុខុន ៖ ទេពេទ្យនៅតែអង្គភាពពេទ្យចឹង ទៅធ្វើពេទ្យរហូតទៅ ដល់ពេទ្យសមាហរណកម្មចឹងរដ្ឋាភិបាល យើងឲ្យទៅរៀនពេទ្យរៀនអីបានសញ្ញាបត្របានអី យើងនៅធ្វើពេទ្យបន្តទៀតទៅណាសនៅទល់ ឥឡូវហ្នឹង ។

ឈុនលី ៖ គាត់ធ្វើពេទ្យនៅឯណា?

សុខុន ៖ នៅហ្នឹងនៅឃុំម៉ាលៃយើងហ្នឹងនៅស្រុកម៉ាឡៃ ។

ឈុនលី ៖ ឈ្មោះអីគេគ្រួសារអ៊ី?

សុខុន ៖ នេះឈ្មោះហាន់ ឡាប់ សែហាន់នេះ ។

ឈុនលី ៖ ចាស! ហើយដូចយើងរស់នៅខ្លួនចឹង ហើយអឹប្រៀបធៀបទៅហ្នឹងសម័យនោះដែលមានអង្គការ គេដូយមានស្បៀងអីចឹងអ៊ឹគិតថាមួយណាស្រួលជាង?

សុខុន	:	អាហ្នឹងវាម្យ៉ាងម្នាក់រស់នៅក្នុងសង្គមនោះសង្គមស្អាតស្អំ រស់នៅយើងខំធ្វើការងារដើម្បីកសាងប្រទេស រស់នៅឥឡូវទាល់តែយើងខំបើយើងមិនខំអត់ហ្នឹងឯង ព្រោះអីយើងកើតឯកជនហើយ ។

ឈុនលី	:	ចាស?

សុខុន	:	ទ្រព្យសម្បត្តិឯកជន អានេះគេហៅថាប្រជាធិបតេយ្យហើយយើងប្រជាធិបតេយ្យរកស៊ីសេរី ហើយ ។

ឈុនលី	:	តែអ៊ីគិតថាមួយណាសប្បាយជាង?

សុខុន	:	ពីមុនវាស្អាតស្អំវាមិនបានតាមគោលបំណងយើងវាអត់បានតែរស់នៅសព្វថ្ងៃ វាធម្មតាទៅ ។ មកដល់ឥឡូវបើនិយាយវាចេះតែឃើញទី១ជក់ម៉ា ក្មេងជក់ម៉ា លក់ថ្នាំញៀនដឹកស្រាស្រវឹងកើត ចោរកើតអីបើពីមុនអត់ទេ យើងរស់នៅសុខសាន្ត តែចង្រៃប្រទេសយើងវាច្របូកច្របល់ ។

ឈុនលី	:	បើគិតទៅស្រុកនេះគេបង្កើតក្រោយសមាហារណកម្មចឹងហ្អីអ៊ី?

សុខុន	:	ស្រុកម៉ាឡៃមុនដំបូងគេហៅភ្នំម៉ាឡៃ មុនដំបូងគេហៅភូមិដូង ហៅបឹងត្រកួនហៅស្រុកមួយរយ ចឹងទៅណាសពេលរត់មកដំបូងគេហៅស្រុកមួយរយពេទ្យ៨៨ចឹងទៅ ។

ឈុនលី	:	តែពេលអ៊ីមកនៅកាល៧៩គេហៅភូមិដូងហើយចឹង?

សុខុន	:	គេហៅភូមិដូង អូរស្រឡៅ ភូមិដូង ចំការចេក បឹងបេង ហើយឥឡូវក៏វានៅឈ្មោះហ្នឹងដែរភូមិសង្កែនៅវាលហាត់ចឹងទៅកើតជាភូមិជាឃុំអស់ហើយព្រោះឥឡូវថ្នាំញៀនអីសំបូរណាស់ ។

ឈុនលី	:	សំបូរ? ប្រុសហ្អីអ៊ី?

សុខុន	:	ប្រុសៗ ។

ឈុនលី	:	ស្រីមានដែរ?

សុខុន	:	ស្រីមិនសូវមានទេ ។ មានឆក់បូន់តែឥឡូវមិនសូវមានច្រើនទេ...អើអ្នករកស៊ីអាហ្នឹង មិនដែលអ្នក តូចទេ វាមានសុទ្ធពីថ្នាក់កំពូលមកដល់ក្រោម ។

ឈុនលី	:	ចុះអ៊ីមានបងប្អូនដឹងថាអ៊ីមកនៅទីនេះដែរអត់តាំងពីអ៊ីមកនៅដំបូង៨៩ ៩០អី?

សុខុន	:	ហ្អស? កាលនោះអត់មានអ្នកណាដឹងទេទាល់តែឆ្នាំ៩០បានដឹង ។

ឈុនលី	:	យូរម៉្លេះ?

សុខុន   :   ចុះម៉េចទាក់ទងបានបើយើងនៅសង្គ្រាមនោះទៅប្រកណា ដល់ពេលឆ្នាំ៩០ ៩១ ៩២ យើងទាក់ទងបានហើយណាសចេញ ទៅដល់យាយអតយាយអី បងប្អូនយើងមកសួរទៅអ្នករកបងប្អូន យើងសរសេរសំបុត្រផ្ញើរូបថតទៅចុះឡើង ដល់ជំនាន់អ៊ុនតាក់ខ្ញុំបានទៅលេងស្គាល់គ្នាទៅស្រុះសាយទៅ បានបងប្អូនគេទៅលេងច្រើន ។

ឈុនលី :   ចុះដែលមានបងប្អូនអឹមកលេងដល់នេះដែរអត់?

សុខុន   :   មាន ។

ឈុនលី :   ចុះឪពុកម្តាយអឹ?

សុខុន   :   ពុកខ្ញុំស្លាប់ទៅតាំងពីឆ្នាំ៧៥ ហើយម្តាយខ្ញុំទើបតែស្លាប់បីឆ្នាំមុន ។

ឈុនលី :   ចុះគាត់មកលេងនេះដែរ?

សុខុន   :   ម៉ោ! ខ្ញុំយកគាត់មកហើយជិះឡានត្រលប់ទៅវិញ ។

ឈុនលី :   អត់អីទេ? ចេញចូលបានចឹង?

សុខុន   :   ចុះមានអ្នកណាចាប់អ្នកណាអីទៅមកធម្មតា អ្នកជួញដូរយកគោយកអី ត្រីងៀតទៅ ជំរុំគាង៉ុកអី មានអីធម្មតាអត់មានអ្នកណាចាប់ទេ ។

ឈុនលី :   ចុះឥឡូវអឹខស្សារាហ៍ទៅលេងស្រុកកំណើតទេ?

សុខុន   :   ខ្ញុំអត់សូវបានទៅទេ ពីរឆ្នាំនេះអត់សូវបានមានលុយមានកាក់អី ។ ខ្ញុំទៅលេងញឹកដែរជួនកាល មួយឆ្នាំពីរដង មួយឆ្នាំម្តង ពីរឆ្នាំម្តងទើបតែខានពីរឆ្នាំនេះទេ ។

ឈុនលី :   ចុះកាល៩៣គាត់មកលេងអឹ ឆ្នាំណាអឹទៅលេងគាត់វិញ?

សុខុន   :   កាលខ្ញុំទៅ....កាលនោះ៩១ ៩២គាត់មកលេង ។

ឈុនលី :   ចុះអឹទៅ?

សុខុន   :   ខ្ញុំទៅលេង...គាត់នឹកខ្ញុំគាត់មកដល់ខ្ញុំនឹកគាត់ខ្ញុំទៅជិះឡានដល់ៗផ្ទះ ។

ឈុនលី :   ចុះដល់ពេលទៅជិបូងចឹងម៉េចដែរអ្នកស្រុកអ្នកភូមិ?

សុខុន   :   ទៅជិបូងចឹងគេមកជួបជុំគ្នាស្គាល់សុទ្ធតែអ្នកស្រុកអ្នកភូមិ ។

ឈុនលី :   ចុះដូចអឹមកនៅតំបន់នេះ ចឹងគេអត់គិតថាអឹធ្លាប់មកនៅជាមួយខ្មែរក្រហម ចឹងគេស្អប់គេខឹងអីទេ?

សុខុន :   ទេ...ទៅគេដេរខ្មែរក្រហមខ្មែរអីដែរ
តែខ្ញុំថាចឹងឯងខ្ញុំថាពួកឯងនេះក៏ខ្មែរក្រហមដូចគ្នាខ្ញុំមិនខ្លាច ទេ ។

ឈុនលី :   មានអ្នកនិយាយចឹងដែរ...និយាយលេងទេអ្ហី?

សុខុន ៖ និយាយលេង អ្នកខ្លះគេមិនយល់និយាយថា "មើលខ្មែរក្រហម" ខ្ញុំថាពួកឯងនេះ ក៏ខ្មែរក្រហមដែរ អ្នកដឹកនាំសព្វថ្ងៃក៏ខ្មែរក្រហមដែរ ខ្មែរក្រហមដូចគ្នាទេ បើកុំតែមានខ្មែរក្រហមស្មានតែអ្នក ឯងបានរស់ដល់សព្វថ្ងៃអ្ហី? ទំនប់ ប្រឡាយ ប៉ុល ពត អីកុំតែបានទំនប់ហ្នឹងទេបានធ្វើស្រែស៊ីនោះ តែក្មេងក្រោយៗដេរតាប៉ុលពត ក៏ដេរទៅតែបើអ្នកដឹកនាំគេនៅស្រួលគេអត់ដេរទេត្បិត អីគាត់ជាអ្នកដឹកនាំមួយត្រឹមត្រូវដែរ ខ្ញុំអត់ខ្លាចទេទៅស្រុកទៅអីថាពួកឯងទាំងអស់គ្នាសុទ្ធតែ ខ្មែរក្រហមដែរ ម៉ែឪយើងម៉ែឪអូនឯងក៏ធ្លាប់រស់នៅក្នុងសម័យនោះដែរ តែមិនដឹងពិបាកឬ ស្រណុកខ្ញុំមិនដឹងទេ។

ឈុនលី ៖ កាលនោះគាត់នៅកុមារ ម៉ែខ្ញុំ

សុខុន ៖ ចាស៎ ហើយបើខ្ញុំកូនអាយុជិតសាមហើយព្រោះបើខ្ញុំការតាំងពីនៅភ្នំពេញ កូនអាយុមិនចេះតិច តែខ្ញុំមិនយកៗ គេមិនបង្ខំទេបើយើងមិនយក គេថាទាល់តែខាងស្រីខាងប្រុសត្រូវគ្នាបានគេបាន គេរៀបការឲ្យអាហ្នឹងឯកសារគេចេញមកចឹង ដូចតែម៉ែឪយើងបច្ចុប្បន្នចឹង បើគេចូលដណ្ដឹង ម៉ែឪអូនឯងឲ្យតែបើអូនឯងអត់ស្រឡាញ់យកទៅមិនមានបញ្ហា?

ឈុនលី ៖ ចាស

សុខុន ៖ ឥឡូវនេះសិទ្ធិគេជ្រើសរើសដោយខ្លួនគេណាស

ឈុនលី ៖ ចុះដល់ពេលខ្មែរក្រហមផ្ដាច់ខ្លួនចឹងប្រជាជនត្រូវរវូវគ្នា?

សុខុន ៖ ចុះមានអី?

ឈុនលី ៖ អត់មានអ្នកណាខឹងគ្នាទេ?

សុខុន ៖ អត់ទេ...គ្មានអ្នកណាខឹងទេ គ្មានអ្នកណារស់នៅសុខស្រួលដូចខ្មែរក្រហមទេ អ្នកខាងក្នុងមកដាំ បាយឲ្យស៊ីទាំងឆ្នាំងៗទៀតៗ

ឈុនលី ៖ យើងដាំបាយឲ្យ?

សុខុន ៖ ដាំបាយទទួល ដូចថាមានអ្នកណាមកមិន ដែលស្គាល់ចឹងអត់មានកន្លែងសំរាកដាំបាយឲ្យហូបទៀតៗ ម្នាក់ៗថាខ្លាចណាស់ខ្មែរក្រហមតែមកដល់ដាន់ចំខ្មែរក្រហមថាអីហ្នឹងទេ ខ្មែរក្រហម? ខ្ញុំថាហ្នឹងខ្មែរក្រហម ហើយគេថាស្មានតែខ្មែរក្រហមស៊ីស្លឹកឈើ ខ្ញុំថាស្អែកស៊ីស្លឹកឈើ ហើយបើខ្មែរក្រហមស៊ីស្លឹកឈើ មិនមានខ្មែរក្រហមមានឈ្មោះលើឆាកអន្តរជាតិទេៗ

ឈុនលី ៖ សុទ្ធតែផ្ញើលគាមគ្នាៗ

សុខុន ៖ សិតតែខ្មែរក្រហមស៊ីស្វីកឈើ។ តាមពិតទៅអ្នកណាក៏ជាខ្មែរក្រហមដែរ ហើយអ្នកពីខាងក្នុងនោះ មកកុំភ័យថាអត់បាយមកនេះមានតែខប្តូម ចឹងបានថាអ្នកដែលខ្លាចខ្មែរក្រហមហ្នឹង មករកស៊ីតែកន្លែងខ្មែរក្រហមទៀត ខ្លះមករកស៊ីនៅនេះមានៗណាស់អូន។

ឈុនលី ៖ មកពីណាវិញ?

សុខុន ៖ មកពីខាងគ្រប់ស្រុកគ្រប់ខេត្ត មកចឹងរកស៊ីមានៗណាស់យូរទៅមានកើតផ្ទះថ្មអី បើខ្មែរក្រហម រកស៊ីមិនសូវមានទេដោយសារអី ដោយសារអត់មានដើមទុន គេមានពីអាមេរិកពីកាណាដា ចិនបារាំងអីទៅគេមានដើមទុន ។

ឈុនលី ៖ ដូចអ៊ីធ្លាប់មកនៅទីនេះស្រឡាញ់ទឹកដីនៅទីនេះ ចឹងចុះបើឲ្យអ៊ីទៅនៅជិតឪពុកម្តាយវិញម៉េចដែរ?

សុខុន ៖ នៅក្នុងយើងអត់មានទៅនៅជិតឪពុកម្តាយ ដោយសារដីតិចៗរកស៊ីអីអត់បានទេ បើយើងនៅនេះ មានដីចំការដីស្រែតិចតួច យើងរស់បានដីយើងដែលចាប់បាន បើទៅនៅក្នុងខ្ញុំអត់ទៅទេបើទៅលេងបានចុះបើចែកដីប៉ុន្មាន១០ម៉ែត្រអី បើទៅលេងបងប្អូនបានធ្លាប់រស់នៅជាមួយមិត្តភក្តិ យើងច្រើនចឹងទៅចិត្តវានៅឯណោះស្រុកចេះនឹកដែរ តែវាអត់មានកេរ្តិ៍អាករចឹងទៅ ។

ឈុនលី ៖ ដូចយើងនៅឆ្ងាយចឹង បើយើងប្រៀបធៀបពីទំនាក់ទំនង រវាងអ្នកជិតខាងនិងបងប្អូនយើងចឹង មួយណាជិតស្និទ្ធជាង?

សុខុន ៖ អារឿងបងប្អូននេះ មានតែអ្នកជិតខាងទេ ដែលជិតស្និទ្ធជាងពេល ដែលយើងឈឺថ្កាត់អីមានតែ អ្នកជិតខាងទេ ជួយមើលបងប្អូនយើងពឹងមិនបានទេ ទោះជាមានម៉េចក៏ដោយបើនៅជិតទៅ ចេះតែពឹងបានទៅណាស ។ ពេលនៅឆ្ងាយចឹងនាមតែបងប្អូនទេតែអ្នកនៅជិតនេះជួយ ពេលយើងឈឺថ្កាត់អី ។

ឈុនលី ៖ ចឹងទឹកចិត្តអ៊ីដក់មកខាងនេះច្រើនជាងអ្វី?

សុខុន ៖ ខ្ញុំនៅភូមិណាខ្ញុំស្រឡាញ់ញាតិមិត្តនៅភូមិនោះ ស្រឡាញ់គ្នាធ្វើម៉េចកុំឲ្យមានល្អក់កករ តែយើងរស់នៅអត់ចេះសាមគ្គីគ្នា ពេលយើងឈឺថ្កាត់អត់មានអ្នកណាមើលយើងទេ ។ ញាតិមិនស្ថិតនៅលើ ការស៊ីចុកលើសំភារៈ ដែលហុចឲ្យគ្នាអត់ទេយើងរាប់គ្នាពេលដែលយើងឈឺ កូនចៅមិននៅអី យើងទុកចិត្តណាស ដូចថាបងអើយ។ ខ្ញុំមិននៅខ្ញុំផ្ញើរផ្ទះអីចឹងអាហ្នឹងសុខទុក្ខយើងដែលយើងរស់ ។ រឿងបងប្អូនយើងទុកមួយឡែកតែបងប្អូនក្នុងភូមិ

យើងរាប់គ្នាពេលដែលយើងឈ្លោះ ប្រកែកគ្នាយកសត្រូវមកដាក់ខ្លួនក៏អត់ទេ ស្រឡាញ់ញាតិមិត្តល្អកល្អីនដាក់គ្នា មានតែញាតិមិត្ត នេះហើយ ដែលយើងស្រឡាញ់គ្នាដែលយើងទុកចិត្តបាន ។

ឈុនលី : មើលទៅបងប្អូននៅទីនេះស្រឡាញ់គ្នាណាស់?

សុខុន : អត់អីទេនៅទីនេះនៅម្ដុំនេះអត់មានចេះលួចទេ យើងអត់ចេះអីទេ ។ ចឹងបានថាអាការរាប់អានគ្នានេះ មិនសំខាន់លើការស៊ីចុកលុយកាក់អីទេ សំខាន់លើទឹកចិត្តស្មោះត្រង់នឹងគ្នាស្រឡាញ់គ្នា ។

ឈុនលី : ចុះអ៊ីខ្ញុំឆ្ងល់ថាអីថាទៅស្រុកដំបូងគេថាខ្មែរក្រហមអាក្រក់ ខ្មែរក្រហមមកហើយអីចឹង...

សុខុន : ហ្នួស1ដូចអ្នកមកពីឆ្ងាយចឹងណាស ថាខ្លាចខ្មែរក្រហមណាសតែការពិតមកក្នុងតំបន់ខ្មែរក្រហមទាំងអស់ដូចថា កាប់សម្លាប់អីអត់ទេ អូនអើយ1ខ្ញុំហើយកាលនៅផ្ទះចាស់អ៊ី អ្នកតាកែវ អ្នកកំពត ចឹងកងទ័ពយើងជូនមកថាស្គាល់អ្នកនេះស្គាល់អ្នកនោះចឹងទៅណាស ឧទាហរណ៍ថាស្គាល់ខ្ញុំអ៊ីចឹង នាំគ្នាដាំបាយដាំអីទទួលមានគេមកផ្សេងទៀត យើងដាំបាយទទួលដែរទៅណាសរួច ហើយគាត់ទៅរកបងប្អូននៅជំរុំតាង៉ុកអីចឹង ដល់រកឃើញគាត់មកវិញ មកស្នាក់នៅផ្ទះយើងចឹងទៅ ដល់គាត់ចេញទៅគាត់លា យើងទៅហើយមានថ្នាំពេទ្យថ្នាំអីយើងឲ្យគាត់ខ្លះទៅណាស ។

ឈុនលី : ចឹងបានន័យថាអាឡូង៩១ ៩២ ៩៣ហ្នឹងសំបូរអ្នកមករកបងប្អូន?

សុខុន : ហ្នួស1មកច្រើនណាស់អូនពេលអ៊ុនតាក់មកហ្នឹងអ្នកខ្លះគេផ្ញើរសំបុត្រទៅអ្នកខ្លះមករក ។

ឈុនលី : ផ្ញើរតាមអីគេទៅ?

សុខុន : ហ្នឹ1 ចុះដូចអូនឯងនៅភូមិហ្នឹងដូចនៅភូមិម៉ាឡៃ ហើយម្នាក់ទៀតនៅភូមិដំបូកវិលចឹងសរសេរអក្សរទៅដូចម៉ែខ្ញុំនៅភូមិដំបូកវិលឈ្មោះ ក ឈ្មោះ ខ ចឹងទៅមានលោកការ ។

ឈុនលី : ចឹងមានអ្នករត់សំបុត្រ?

សុខុន : មាន យើងឲ្យលុយគេខ្លះទៅឲ្យគ្នាធ្វើដំណើរទៅ ។

ឈុនលី : ម៉េចក៏លាក់ការចឹង?

សុខុន : លាក់ការទី១វាំនៅតំបន់ប្រទាញប្រទង់ យើងលាក់ទៅកុំឲ្យឮដល់អាខ្លះវាគិតថាយើងទាក់ទងគ្នាឲ្យការគ្នាដល់ម៉ែឪ  យើងដឹងមកជាមួយអ្នកហ្នឹងទៅអត់មានអីទេ អត់មានបញ្ហាអីទេ ខ្ញុំជិះឡានទៅផ្ញើរូបថតទៅទៀតខ្លះ ទៅអាមេរិកទៅអីទៅដល់សមាហារណកម្មហើយមកច្រើនតែម្ដង ។

ឈុនលី : ចុះមានបងប្អូនយើងក្រោយសមាហារណកម្មហើយ មានអ្នករត់ទៅនៅខាងក្នុងវិញដែរអត់?

សុខុន : អាហ្នឹងមាតុភូមិពួកកាកបាទគេយកទៅណាស់ទៅពីជំរុំគេចែកលុយចែកផ្ទះអីណាស់។

ឈុនលី : ចែកនៅឯណាទៅ?

សុខុន : ចែកនៅស្រុកខ្មែរយើង ឧទាហរណ៍ថាខ្ញុំនៅភូមិម៉ាឡៃចឹងគេយកមកដាក់នៅភូមិម៉ាឡៃចឹងមកនៅ ភូមិ៩៣ចឹងគេជូនយើងទៅភូមិ៩៣ ។

ឈុនលី : ចុះដូចអ្នកមកពីខេត្តកណ្តាលទៅនៅខេត្តកណ្តាលវិញអីចឹង?

សុខុន : ហ្អស។ អាហ្នឹងដូចថាម៉ែឪគេខ្លះគេមានកូនតិចចឹង គេចង់យកកូនគេទៅនៅស្រុកវិញចឹងគេទៅៗ ណាស ។

ឈុនលី : ទៅច្រើនទេអី?

សុខុន : ទៅ ទៅខ្លះមកវិញខ្លះចឹងទៅ ។

ឈុនលី : គាត់ទៅហើយត្រលប់មកវិញ?

សុខុន : ចាស៎ អ្នកខ្លះទៅហើយអត់ធ្លាប់នៅចឹងគេត្រលប់មកវិញ ។

ឈុនលី : ភាគច្រើនឆ្នាំណាដែលគេទៅហ្នឹង?

សុខុន : ឆ្នាំណាមានតែឆ្នាំសមាហារណកម្មហើយហ្នឹង ។

ឈុនលី : ឆ្នាំណា ឆ្នាំ៩៦?

សុខុន : ឆ្នាំ៩៦ ៩៧ ៩៨ ៩៨ហ្នឹងគេចេះតែទៅបន្តបន្ទាប់ហ្នឹង ម៉ែឪខ្លះគេធូរធារគេចេះតែយកកូន គេទៅរកស៊ីចឹងទៅហើយខ្លះទៅគេមកវិញចឹងទៅទៅមកៗវិលពេញតែហ្នឹង ។

ឈុនលី : ចុះដល់ពេលយូរទៅវាសេរីហើយ ។

សុខុន : ចុះមានទៅអីបើគេចាយលុយចាយអី ហើយយើងចង់ទៅនៅឯណាក៏បានដែរគ្រាន់តែប្រាប់មេឃុំ មេភូមិទៅថាឥឡូវយើងទៅនៅស្រុកជាមួយម៉ែឪវិញចឹង គេសរសេរសំបុត្រអី ឲ្យទៅដល់ឯណោះគេទទួលទៅ ។ ដូចខ្ញុំទៅលេងចឹងគេប្រាប់ថា កូនខ្ញុំបាត់ដប់ម្ភៃឆ្នាំ ហើយឥឡូវមកលេងចឹងទៅ គេមានថាអី ហើយយើងប៉ុន្មានថ្ងៃដប់ថ្ងៃចឹង យើងត្រលប់ទៅវិញប្រាប់គេទៅ ។

ឈុនលី : ចុះអ៊ំបើសិនជាយើងចង់ផ្សះផ្សាគ្នារវាងអ្នកខាងក្នុង ដែលគាត់ស្អប់ខ្មែរក្រហម អីចឹងអ៊ំគិតថា តើអ្នកដែលរស់នៅឆ្ងាយពីគ្នា ឬអ្នកនៅជិតគ្នាដែលអាចផ្សះផ្សាគ្នាបានលឿនជាង?

សុខុន ៖ មិនថាជិតមិនថាឆ្ងាយទេ អូនដល់ពេលគាត់មក យើងនិយាយពន្យល់គាត់ទៅដល់គាត់យល់ទៅដូចតែ យើងចឹងថាខ្មែរក្រហមជាមនុស្សធម្មតាដល់តែយូរទៅមានទៅអី អ្នកខ្លះមកអត់អីនៅមកសុំយើង នៅដល់តែប្រាប់ថាខ្មែរក្រហមចឹង ទៅមានទៅរាក់ទាក់គ្នាសឹងអី ៗ

ឈុនលី ៖ ចឹងសំខាន់បានជួបគ្នា?

សុខុន ៖ យើងបានជួបគ្នាទៅនិយាយតៗគ្នា ថាអញទៅហើយ មិនដែលខ្មែរក្រហមឯណាអាករមនុស្សទេ ទៅស្រួលសឹងអី ចឹងទៅចេះតែមានមនុស្សចូលមកហើយទាក់ទងគ្នាទៅមកៗ បើកាប់សំលាប់គ្នា ដែលមានមនុស្សឯណាមកដូចអូនឯងចឹង មកដំបូងសុទ្ធតែមកស្វែងរកការពិតហើយ ៗ បើអូនឯងមកចឹង អត់ស្គាល់ផ្ទះចឹងជូនរកទៀត ដាំបាយឲ្យហូបឲ្យផ្ទះស្នាក់នៅ ហើយជួនកាលជូនទៅទៀត ដូចថានៅតាង៉ុកចឹងណាសគេមានឡានមានអីជូនទៅចឹង កាលនោះយើងមិនមានលេខ ទូរស័ព្ទអីដូចឥឡូវទេ ៗ

ឈុនលីៈ ចុះអ៊ំមានដឹងទេពីប្រវត្តិដំបូងរបស់ស្រុកម៉ាឡៃហ្នឹងវាម៉េចទៅ? វាមានឈ្មោះស្រុកអីមួយពីមុនទេ មុននឹងដាក់ឈ្មោះស្រុកម៉ាឡៃហ្នឹង ៗ

សុខុន ៖ ទេ...ខ្ញុំមិនដឹងទេត្បិតអីកាលពី មុនម៉ាឡៃវាមានស្វាយនៅអី ដល់ឥឡូវគេដាក់នៅបន្ទាយមានជ័យ ៗ

ឈុនលី ៖ ចុះពីដំបូងដែលអ៊ំមកហ្នឹងនៅខេត្តអីហើយ?

សុខុន ៖ តំបន់នេះពីមុនមកមិនដឹងមានខេត្តអីទេដឹងតែភូមិដូង ស្រុកម៉ាឡៃតែប៉ុណ្ណឹង ៗ

ឈុនលី ៖ គេហៅស្រុកម៉ាឡៃចឹង?

សុខុន ៖ ឥឡូវស្រុកម៉ាឡៃហ្នឹងឯង ដឹងថាមុនដំបូងនៅអូរស្រឡៅ ពេទ្យអូរស្រឡៅ ផ្លូវធំណាស់ៗ នៅអូរ ស្រឡៅ នៅ៩៣ នៅអូរទំព័រ អាអូរទំព័រហ្នឹងវាមានដើមទំព័រនៅទីនោះ ៗ ទៅពីនោះនោះទៀត មានបន្ទាយទី២ អាបន្ទាយទី២នោះពីដើមកន្លែងធ្វើសង្គ្រាមណាស់ៗ បន្ទាយទី២ឡូងខង បន្ទាយទី១ខ្លាងរាប់ចេះតែហូរហែរចឹងទៅ ហើយទៅទំនប់ស្វាយ មានដើមស្វាយគេចេះតែដាក់ចឹងទៅ ណាស រហូតមកដល់សាស្តា ៗ

ឈុនលី ៖ ចឹងឈ្មោះម៉ាឡៃហ្នឹងគេដាក់ក្រោយពេលសមាហរណកម្មហើយ?

សុខុន ៖ អត់ទេ មកតាំងពីខ្ញុំមកនៅមុនដំបូងតាំងពីនៅព្រៃតាំងពីយួនដេញដំបូងគេថាភ្នំម៉ាឡៃៗ ភ្នំវ៉ាង អីន៊ ៗ

ឈុនលី ៖ ចឹងដោយសារតែមានភ្នំម៉ាឡៃបានគេហៅស្រុកម៉ាឡៃហ្នឹង?

សុខុន : ចា៎ ភ្នំម៉ាឡៃ ។

ឈុនលី : ភ្នំម៉ាឡៃហ្នឹងធំដែរ?

សុខុន : ទេ...មិនដឹងជាភ្នំណាទេនៅនោះទេដឹង ។

ឈុនលី : អត់ដែលទៅទេអី?

សុខុន : ទៅតើ តែភ្នំហ្នឹងវាតូច ។

ឈុនលី : ចឹងភ្នំហ្នឹងធំជាងគេបានគេយកឈ្មោះហ្នឹងមកព្រោះអីភ្នំវ៉ាងអីមានដែរ?

សុខុន : ទេភ្នំវ៉ាងក៏ធំដែរតែមិនដឹងយ៉ាងម៉េច បានគេហៅភ្នំម៉ាឡៃៗចឹង ក៏ជាប់ងាភ្នំម៉ាឡៃចឹង រហូតទៅក៏ ដាក់ស្រុកម៉ាឡៃចឹងទៅ ។

ឈុនលី : អឹបើយើងគិតតាមទិស ស្រុកម៉ាឡៃហ្នឹងស្ថិតនៅប៉ែកខាងណានៃខេត្តបន្ទាយមានជ័យ?

សុខុន : ប៉ែកខាងណា ប៉ែកខាងលិចនេះឯងជាប់ថៃ ។

ឈុនលី : នៅខាងលិចហ្នូង?

សុខុន : ថ្ងៃលិចខាងនេះ កន្លែងនេះពីមុនគេហៅថាតំបន់ត្រីកោណ ។

ឈុនលី : ត្រីកោណខាងណាខ្លះអាហ្នឹង?

សុខុន : ខ្ញុំអត់ដឹងទេ តែមេៗប្រជុំគេហៅថាតំបន់ត្រីកោណមិនដឹងដែរ ។

ឈុនលី : សម័យណាគេហៅចឹង?

សុខុន : សម័យសង្គ្រាម ។

ឈុនលី : អាពេលយើងរត់មកហើយហ្នឹង?

សុខុន : ចា៎ អាហ្នឹងមិត្តថៃនិងយើងសាមគ្គីគ្នា គាត់ឲ្យកន្លែងយើងស្នាក់នៅឲ្យយើងមានជំរកមាន ស្បៀង ។

ឈុនលី : ជំរុំហ្នឹង?

សុខុន : ចា៎ គេហៅតំបន់ត្រីកោណ ។

ឈុនលី : យើងមានខាងយើងមួយខាងថៃមួយតែមួយទៀតអត់ដឹង?

សុខុន : អានេះខ្ញុំដឹង មើលយើងនៅខាងលិច ឲ្យតែនៅខាងលិចគឺថៃចឹងហ្នូង ព្រោះបើជិះទៅទៀត ខ្ញុំមិន ដឹងនៅឯណាដែរ តែបើខ្ញុំនៅនេះលិចចំ ។

ឈុនលី : ភាគច្រើនប្រជាជននៅទីនេះគាត់ដាំចំការច្រើន?

សុខុន : ភាគច្រើនអ្នកចំការអ្នកផ្សារខ្លះទៅចំការខ្លះទៅ ខ្ញុំមានផ្សារអីមានតែចំការតិចតួច ។

ឈុនលី : ចុះគ្រួសារអ៊ឹនៅធ្វើពេទ្យទៀត?

សុខុន ៖ ធ្វើពេទ្យ ។

ឈុនលី ៖ គាត់កាន់ខាងអីទៅ?

សុខុន ៖ កាលពីមុនគាត់នៅខាងវះកាត់ដល់ពេលគេបែងចែកគ្នាទៅគាត់ទៅខាងពិគ្រោះជំងឺវិញ

ឈុនលី ៖ ហ្អូស1 នៅខាងពិគ្រោះ ចឹងគាត់រកស៊ីតាមផ្ទះបានដែរ?

សុខុន ៖ អត់ទេ អត់មានទៅរកស៊ីនៅឯណាទេត្បិតអីប្រជាជនតិចពេទ្យច្រើនរកអត់បានទេ ។

ឈុនលី ៖ ចឹងនៅនេះពេទ្យច្រើន?

សុខុន ៖ ចុះបើពេទ្យច្រើនហើយប្រជាជនតិច គេផ្សេងទៅរកបានដែរតែប្តីខ្ញុំគាត់ខ្ជិលកំប៉ិកកំប៉ុក ។

«ចប់»